MEAT INDUSTRY EMPLOYEES' SUPERANNUATION FUND

# សេចក្តីសង្ខេបនៃអត្ថប្រយោជន៍ និងថ្លៃចំណាយ

| | | |
|---|---|---|
| **MIESF បញ្ជូនប្រាក់ចំណេញទាំងអស់របស់ខ្លួនមកជូនសមាជិកវិញ<br>ប្រាក់ទទួលបានវិនិយោគកាន់តែខ្ពស់ - ថ្លៃចំណាយកាន់តែទាប** | | |
| ប្រាក់ចំណូលដែលបានលៃទុក -<br>**MIESF MySuper** | 2015/16 | 5.8% ក្នុង១ឆ្នាំ (6.3% ក្នុង១ឆ្នាំ សម្រាប់ផ្នែកប្រាក់សោធននិវត្តន៍) |
| ជាប្រវត្តិសាស្ត្រ – **MIESF MySuper** | 5 ឆ្នាំជាមធ្យម<br>10 ឆ្នាំជាមធ្យម<br>20 ឆ្នាំជាមធ្យម<br>33 ឆ្នាំជាមធ្យម | 7.9% ក្នុង១ឆ្នាំ (8.7% ក្នុង១ឆ្នាំ សម្រាប់ផ្នែកប្រាក់សោធន)<br>5.1% ក្នុង១ឆ្នាំ (5.7% ក្នុង១ឆ្នាំ សម្រាប់ផ្នែកប្រាក់សោធន)<br>6.8% ក្នុង១ឆ្នាំ (7.6% ក្នុង១ឆ្នាំ សម្រាប់ផ្នែកប្រាក់សោធន)<br>8.5% ក្នុង១ឆ្នាំ (ផ្នែកប្រាក់សោធន ចាប់ផ្តើមក្នុងឆ្នាំ 1995) |
| **High Growth Option**<br>(ជម្រើសកំណើនខ្ពស់) | ចាប់អនុវត្តពីថ្ងៃទី 31 ខែមករា ឆ្នាំ 2009 មូលនិធិផ្តល់ជូនសមាជិកផ្នែកសំខាន់នូវជម្រើសវិនិយោគមួយដែលត្រូវបានយោងថា "High Growth Option" (ជម្រើសកំណើនខ្ពស់)។ អត្រានៃប្រាក់ចំណូលដែលបានលៃទុកសម្រាប់ High Growth Option គឺ 3.0% ក្នុងមួយឆ្នាំ នៅឆ្នាំ 2015/16។<br>អត្រា 5 ឆ្នាំជាមធ្យមគឺ 10.2% ក្នុងមួយឆ្នាំ ហើយអត្រា 7 ឆ្នាំជាមធ្យមគឺ 10.2% ក្នុងមួយឆ្នាំ។ | |
| **ទ្រព្យសកម្មសុទ្ធ មកទល់នឹងថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2016** | | $717 លាន |
| **ទំហំមូលនិធិមកទល់នឹងថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2016** | សមាជិកភាព<br>សមាជិក "សកម្ម" ដែលបានចុះក្នុងបញ្ជី | 23,800<br>1,975 |
| **ថ្លៃចំណាយគ្រប់គ្រងមូលនិធិ** | ការចាត់ចែង $67.60 ក្នុងមួយឆ្នាំ ដកចេញពីគណនីនីមួយៗ (ឡើងទៅ $78 ក្នុងមួយឆ្នាំ ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2017)<br>0.53% ក្នុងមួយឆ្នាំ នៃតុល្យភាពគណនីរបស់លោកអ្នកពេលណាធ្វើវិនិយោគនៅក្នុង MIESF MySuper ឬ 0.37% ក្នុងមួយឆ្នាំនៃតុល្យភាពគណនីរបស់លោកអ្នកពេលណាធ្វើវិនិយោគនៅក្នុង High Growth Option។ ទាំងនេះគឺជាថ្លៃចំណាយទាក់ទិននឹងការធ្វើវិនិយោគរបស់មូលនិធិ។<br>ពុំគិតថ្លៃចំពោះការចូលមកក្នុងមូលនិធិទេ។ ទោះជាយ៉ាងណាក្តី មានការគិតថ្លៃ $35 ចំពោះការដកប្រាក់ចេញពីមូលនិធិមួយលើកៗ។ | |
| **ការការពារធានារ៉ាប់រងនៅពេលស្លាប់<br>នៅពេលមានជំងឺដែលមុខតែនឹងស្លាប់<br>និងនៅពេលមានពិការភាពទាំងស្រុងជាអចិន្ត្រៃយ៍<br>(TPD)<br>93% នៃសមាជិក MIESF បានទទួលការធានារ៉ាប់រង** | សមាជិកដែលមានសិទ្ធិអាយុក្រោម 65 ឆ្នាំ មានការការពារធានារ៉ាប់រងនៅពេលស្លាប់ និងការមានជំងឺដែលមុខតែនឹងស្លាប់ ចំនួន $200,000 ។<br>សមាជិកដែលមានសិទ្ធិអាយុ 65 ទៅ 69 ឆ្នាំសរុប មានការការពារធានារ៉ាប់រងនៅពេលស្លាប់ ចំនួន $35,000។<br>សមាជិកដែលមានសិទ្ធិអាយុ 65 ទៅ 68 ឆ្នាំសរុប មានការការពារធានារ៉ាប់រងនៅពេលមានជំងឺដែលមុខតែនឹងស្លាប់ ចំនួន $35,000។<br>សមាជិកដែលមានសិទ្ធិអាយុក្រោម 39 ឆ្នាំ មានការការពារធានារ៉ាប់រងនៅពេលមានពិការភាពទាំងស្រុងជាអចិន្ត្រៃយ(TPD) ចំនួន $200,000។<br>កម្រិតនៃការការពារធានារ៉ាប់រងនឹងកាត់បន្ថយយ៉ាងលឿន ចាប់ពីអាយុ 39 ឆ្នាំទៅអាយុ 64 ឆ្នាំ ហើយគឺ $0 ចាប់ពីអាយុ 65 ទៅ។<br>$5.60 ក្នុង១សប្តាហ៍ត្រូវបានដកចេញពីគណនីរបស់សមាជិកដែលមានសិទ្ធិម្នាក់ៗដើម្បីគ្របដណ្តប់លើថ្លៃចំណាយ។<br>លោកអ្នកអាចពិនិត្យមើលកូនសៀវភៅការធានារ៉ាប់រងរបស់មូលនិធិចុះថ្ងៃទី 22 ខែតុលា ឆ្នាំ 2014 នៅតាមអ៊ីនធើណិតនៅត្រង់ **miesf.com.au/pds**។<br>ការដាក់កំណត់លើការធានារ៉ាប់រងផ្សេងៗមានពន្យល់នៅទំព័រ 3 និង 4 នៃកូនសៀវភៅការធានារ៉ាប់រង។ | |
| **ផ្នែកប្រាក់សោធន (Pension Section)** | សមាជិកដែលមានអាយុ 55 ឬច្រើនជាងនេះ អាចចាប់ផ្តើម MIESF Pension ដោយបង់ "ថ្លៃចំណាយគ្រប់គ្រងមូលនិធិ" ទាបដូចគ្នាដូចមានចែងខាងលើនេះ។ | |
| **ប្រាក់វិភាគទាន ឬប្រាក់រួមចំណែកដោយស្ម័គ្រចិត្ត** | សមាជិកដែលបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត អាចធ្វើបានដោយពុំបង់ថ្លៃចំណាយបន្ថែម ហើយប្រហែលជាអាចមានសិទ្ធិទទួលបានប្រាក់វិភាគទានរួមពីរដ្ឋាភិបាលផងដែរ។ សូមកត់ចំណាំថា ប្រសិនបើលោកអ្នកអាយុ 65 ឆ្នាំ ឬលើសពីនេះ លោកអ្នកនឹងចាំបាច់ត្រូវមានការងារធ្វើយ៉ាងហោចណាស់មានការងារមិនពេញពេល ដើម្បីបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត។<br>ប្រសិនបើលោកអ្នកអាយុ 75 ឬលើសពីនេះ លោកអ្នកពុំអាចបង់ប្រាក់វិភាគទានទាំងនេះចូលទៅក្នុងប្រាក់សោធនចូលនិវត្តន៍ឡើយ។ | |
| **ឧស្សាហកម្មមូលនិធិរបស់លោកអ្នក** | MIESF បានបង្កើតឡើងជាង ៣០ ឆ្នាំមកហើយ។ មូលនិធិនេះប្រតិបត្តិការនៅទូទាំងប្រទេសអូស្ត្រាលី ជាមូលនិធិពហុនិយោជកដែលផ្តល់ជូនប្រាក់សោធនចូលនិវត្តន៍សម្រាប់អ្នកធ្វើការនៅក្នុងឧស្សាហកម្មសាច់។ | |

ព័ត៌មានខាងលើនេះគ្រាន់តែជាសេចក្តីសង្ខេបប៉ុណ្ណោះ។ សូមកត់ចំណាំថាការអនុវត្តន៍វិនិយោគពីអតីតកាល ពុំមែនជាសញ្ញាបង្ហាញដែលអាចទុកចិត្តបាននៃការអនុវត្តន៍នាពេលអនាគតឡើយ។

ព័ត៌មានលម្អិតនៃអត្ថប្រយោជន៍របស់មូលនិធិ ថ្លៃចំណាយ និងការប្រតិបត្តិការអាចរកឃើញនៅក្នុងរបាយការណ៍បង្ហាញប្រាប់អំពីផលិតផល(PDS) ថ្មីចុងក្រោយបង្អស់របស់យើងខ្ញុំចុះនៅថ្ងៃទី 22 ខែតុលា ឆ្នាំ 2015។ ក៏មាន PDS សម្រាប់សមាជិកផ្នែកប្រាក់សោធនផងដែរ ចុះនៅថ្ងៃទី 22 ខែតុលា ឆ្នាំ 2015។

លោកអ្នកអាចមើល PDSs ទាំងនេះនៅតាមអ៊ីនធើណិត **miesf.com.au/pds** ឬប្រសិនបើលោកអ្នកចង់បានច្បាប់ចម្លងជាសណ្ឋានបោះពុម្ព សូមទូរស័ព្ទ 1800 252 099។ លោកអ្នកគួរពិនិត្យមើលរបាយការណ៍បង្ហាញប្រាប់អំពីផលិតផលរបស់មូលនិធិ មុនពេលធ្វើសម្រេចចិត្តដើម្បីទទួលយក ឬទិញ ឬបន្តកាន់កាប់ផលប្រយោជន៍នៅក្នុងមូលនិធិនេះ។

អ្នកទទួលភារៈគ្រប់គ្រងមូលនិធិគឺ Superannuation Fund Pty Ltd របស់និយោជិតធ្វើការនៅតាមឧស្សាហកម្មសាច់។
(ABN 58 005 793 199) (AFSL 239953) (RSE L0001434) MySuper Authorised 17317520544110

MEAT INDUSTRY EMPLOYEES' SUPERANNUATION FUND

# ប្រាក់ទទួលបានពីវិនិយោគដែលមានការប្រកួតប្រជែងខ្លាំងពី MIESF

## ប្រាក់ទទួលបានពីវិនិយោគ

ប្រាក់ទទួលបានពីវិនិយោគ (ដកចេញថ្លៃចំណាយលើការវិនិយោគ និងការបង់ពន្ធដារ) ត្រូវបានលៃទុកសម្រាប់ដាក់បញ្ចូលក្នុងគណនីរបស់សមាជិក សម្រាប់ចំណាច់ឆ្នាំហិរញ្ញវត្ថុថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2016 នេះគឺ:

**5.8%** **សម្រាប់សមាជិករួមដែលបានធ្វើវិនិយោគក្នុង MIESF MySuper**

**3.0%** **សម្រាប់សមាជិករួមដែលបានធ្វើវិនិយោគក្នុង High Growth Option**

**6.3%** **សម្រាប់សមាជិកប្រាក់សោធន**

ឆ្នាំហិរញ្ញវត្ថុ 2015/16 គឺជាអំឡុងពេលលំបាកមួយសម្រាប់អ្នកវិនិយោគ។ ប្រាក់ទទួលបានពីវិនិយោគពីហ៊ុនអូស្ត្រាលី និងអន្តរជាតិ គឺក្បែរ 0%។

**ប្រាក់ទទួលបានពីវិនិយោគ 5.8% ដែលបម្រុងទុកសម្រាប់សមាជិកធ្វើវិនិយោគក្នុង MIESF MySuper គឺជាប្រាក់ទទួលបានពីវិនិយោគដែលមានការប្រកួតប្រជែងយ៉ាងខ្លាំង ហើយប្រហែលជាទីបីខ្ពស់ជាងគេសម្រាប់គណនី MySuper ក្នុងមូលនិធិសោធននិវត្តន៍អូស្ត្រាលី។**

សមាជិកនឹងឃើញឥទ្ធិពល នៃប្រាក់ទទួលបានពីវិនិយោគសោធននិវត្តន៍របស់គេ ដោយការពិនិត្យមើល របាយការណ៍អំពីអត្ថប្រយោជន៍ប្រចាំឆ្នាំរបស់គេ។

ប្រសិនបើលោកអ្នកពុំទទួលបាន របាយការណ៍អំពីអត្ថប្រយោជន៍របស់លោកអ្នកទាន់ថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2016 ទេ សូមទូរស័ព្ទទៅមូលនិធិ។

សូមចំណាយពេលពីរបីនាទីដើម្បីពិនិត្យមើល "សេចក្តីសង្ខេបនៃអត្ថប្រយោជន៍ និងថ្លៃណាយ" សម្រាប់ MIESF ដែលបង្ហាញនៅលើទំព័របន្ទាប់។

## ប្រាក់វិភាគទានធានាសម្រាប់សោធននិវត្តន៍

ប្រាក់វិភាគទានធានាសម្រាប់សោធននិវត្តន៍ដែលខានមិនបាន បង់ដោយនិយោជករបស់លោកអ្នក គឺចំនួន 9.5% នៃប្រាក់ចំណូលធម្មតារបស់លោកអ្នក ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2014។

## MIESF គឺជាឧស្សាហកម្មមូលនិធិរបស់លោកអ្នក

MIESF បានបង្កើតឡើងនៅឆ្នាំ 1981 ដោយ AMIEU។ មូលនិធិបន្តការទទួលគាំទ្រដោយសហជីព។ ក្រុមហ៊ុនទទួលភារៈដែលមើលគ្រប់គ្រងមូលនិធិមានប្រធានឯករាជ្យ ហើយនាយកចំនួនពាក់កណ្តាលឯទៀតត្រូវបានតែងតាំងដោយសហជីព ក្នុងនាមសមាជិក។

គោលបំណងរបស់មូលនិធិគឺ ផ្តល់ជូនកម្មករធ្វើការនៅតាមឧស្សាហកម្មសាច់នូវមូលនិធិសោធននិវត្តន៍មួយដែលមានថ្លៃចំណាយទាប សាមញ្ញ និងមានប្រសិទ្ធិភាព។ គោលបំណងនៃ MIESF MySuper គឺដើម្បីធានានូវសន្តិសុខនៃប្រាក់សោធននិវត្តន៍របស់លោកអ្នក និងដើម្បីផ្តល់នូវអត្រានៃប្រាក់ចំណូលដ៏សមរម្យដែលខ្ពស់ជាងអត្រានៃការប្រាក់របស់ធនាគារក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដោយមិនចាប់យកហានិភ័យហិរញ្ញវត្ថុដែលហួសហេតុពេក។ សមាជិកទាំងឡាយណាដែលអាចទ្រាំទ្រនឹងកម្រិតខ្ពស់នៃហានិភ័យ គេអាចធ្វើវិនិយោគគណនីសោធននិវត្តន៍របស់ខ្លួនមួយផ្នែក ឬទាំងអស់នៅក្នុង High Growth Option ។

## MIESF គឺជា MySuper ដែលបានអនុញ្ញាត

អ្នកទទួលភារៈគ្រប់គ្រងមូលនិធិ MIESF ត្រូវបានអនុញ្ញាតដោយ Australian Prudential Regulation Authority ដើម្បីផ្តល់ជូន MIESF MySuper សម្រាប់សមាជិករបស់ខ្លួន។

ក្នុងករណីជាច្រើន ច្បាប់រដ្ឋាភិបាលតម្រូវឲ្យនិយោជកបង់ប្រាក់វិភាគទានសោធននិវត្តន៍ ទៅឲ្យមូលនិធិណាមួយដែលផ្តល់គណនី MySuper។ គណនី MySuper ទាំងនេះត្រូវបានសន្មត់ថាជាជម្រើសមួយដែលមានថ្លៃចំណាយទាប សាមញ្ញ ហើយមានប្រសិទ្ធិភាពសម្រាប់សមាជិក ដើម្បីដាក់បញ្ចូលប្រាក់វិភាគទានសម្រាប់ប្រាក់ធានាសោធននិវត្តន៍របស់ពួកគេ។

ប្រសិនបើលោកអ្នកមិនបានជ្រើសរើស មូលនិធិសោធននិវត្តន៍ដោយសកម្មដែលនិយោជករបស់លោកអ្នកបង់ប្រាក់វិភាគទានរបស់លោកអ្នកទៅ ឬលោកអ្នកមិនបានធ្វើជម្រើសវិនិយោគណាមួយទេ ប្រាក់វិភាគទានរបស់លោកអ្នកត្រូវតែបង់ទៅគណនី MySuper មួយ។

ប្រសិនបើបច្ចុប្បន្ននេះ លោកអ្នកជាសមាជិកនៃ MIESF និយោជករបស់លោកអ្នកគួរបន្តបង់ប្រាក់វិភាគទាន ក្នុងនាមលោកអ្នកទៅ MIESF។

## MIESF មានថ្លៃឈ្នួលទាប

គ្រប់ផលិតផល MySuper ត្រូវបានសន្មត់ថាមានថ្លៃចំណាយទាប ជាជម្រើសវិនិយោគដ៏សាមញ្ញ ហើយមានការការពារធានារ៉ាប់រងនៅពេលស្លាប់ នៅពេលមានជំងឺដែលមុខតែនឹងស្លាប់ និងនៅពេលមានពិការភាពទាំងស្រុងជាអចិន្ត្រៃយ៍។MIESF MySuper មានលក្ខណៈទាំងអស់នេះ។ នៅពេលក្រោយមក លោកអ្នកគួរតែអាចប្រៀបធៀបផលិតផល MySuper ហើយលោកអ្នកនឹងឃើញថា MIESF គឺជាមូលនិធិសោធននិវត្តន៍មួយដែលមានថ្លៃចំណាយទាបបំផុតក្នុងប្រទេសអូស្ត្រាលី។

Australian Prudential Regulation Authority បានបោះពុម្ពនៅក្នុង "Insight Issue One 2014" របស់ខ្លួន អំពីព័ត៌មានលម្អិតនៃទិន្នន័យដែលប្រមូលបានពីផលិតផល MySuper ដែលបានអនុញ្ញាត។ ថ្លៃចំណាយសម្រាប់ការគ្រប់គ្រង និងការធ្វើវិនិយោគសរុបគិតជាមធ្យមក្នុងមួយឆ្នាំ សម្រាប់សមាជិកម្នាក់ដែលមានតុល្យភាពគណនី $50,000 គឺ $496 នៅក្នុងជួរ $215 ទៅ $1,242។ តាមការប្រៀបធៀបថ្លៃឈ្នួល MIESF MySuper សមមូលគឺ $345 ក្នុងឆ្នាំ 2015/16។

## ការរៀបចំការធានារ៉ាប់រងថ្មី ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2013

ការការពារធានារ៉ាប់រងនៅពេលស្លាប់ដោយបង់ខ្លួនឯងរបស់មូលនិធិ ត្រូវបានដាក់ជំនួសចាប់ពីថ្ងៃទី 1 ខែកក្កដាឆ្នាំ 2013 ដោយមានគោលនយោបាយធានារ៉ាប់រងមួយ។ ការការពារធានារ៉ាប់រងនៅពេលស្លាប់, នៅពេលមានពិការភាពទាំងស្រុងជាអចិន្ត្រៃយ៍ (TPD) និងនៅពេលមានជំងឺដែលមុខតែនឹងស្លាប់ ត្រូវបានផ្តល់សម្រាប់សមាជិកដែលមានសិទ្ធិទាំងអស់។

ការការពារធានារ៉ាប់រង ចំនួន $200,000 សម្រាប់សមាជិកដែលមានសិទ្ធិអាយុក្រោម 65 ឆ្នាំ ត្រូវបានរក្សាទុកឲ្យនៅដដែល។ បច្ចុប្បន្ន អត្ថប្រយោជន៍នេះនឹងត្រូវបើកជូន "មុនកំណត់" នៅពេលមានជំងឺដែលមុខតែនឹងស្លាប់។ សមាជិកដែលមានសិទ្ធិអាយុក្រោម 39 ឆ្នាំ ឥឡូវនេះមានការការពារធានារ៉ាប់រង TPD ចំនួន $200,000។ កម្រិតនៃការការពារធានារ៉ាប់រង TPD នឹងត្រូវកាត់បន្ថយយ៉ាងលឿន ចាប់ពីអាយុ 39 ឆ្នាំ ទៅអាយុ 64 ឆ្នាំ ហើយគឺ $0 ចាប់ពីអាយុ 65 ទៅ។ ការដកប្រាក់ចេញពីគណនីរបស់សមាជិកម្នាក់ៗ ត្រូវបានបង្កើនពី $5 ក្នុងមួយសប្តាហ៍ (សម្រាប់ការការពារធានារ៉ាប់រងនៅពេលស្លាប់ដោយបង់ខ្លួនឯង) ទៅ $5.60 ក្នុងមួយសប្តាហ៍ សម្រាប់ការការពារធានារ៉ាប់រងថ្មី។

ការការពារធានារ៉ាប់រងនៅពេលស្លាប់ និងនៅពេលមានជំងឺដែលមុខតែនឹងស្លាប់ ត្រូវបានបន្ថយពេលចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2014។ សមាជិកដែលមានសិទ្ធិ អាយុពី 65 ទៅ 69 សរុប ឥឡូវនេះបានទទួលការគ្របដណ្តប់ចំនួន $35,000 នៃការការពារធានារ៉ាប់រងនៅពេលស្លាប់។ សមាជិកដែលមានសិទ្ធិ អាយុពី 65 ទៅ 68 សរុប ឥឡូវនេះក៏បានទទួលការគ្របដណ្តប់ចំនួន $35,000 នៃការការពារនៅពេលមានជំងឺដែលមុខតែនឹងស្លាប់ដែរ។ ការដកប្រាក់ចំនួន $5.60 ក្នុងមួយសប្តាហ៍ ក៏អនុវត្តចំពោះការការពារធានារ៉ាប់រងនេះដែរ។

ព័ត៌មានលម្អិតបន្ថែមទៀតស្តីអំពីការការពារធានារ៉ាប់រង មានផ្តល់នៅក្នុងកូនសៀវភៅការធានារ៉ាប់រងរបស់មូលនិធិ ចុះថ្ងៃទី 22 ខែតុលាឆ្នាំ 2014 ដែលលោកអ្នកអាចអាននៅតាមវិបសាយ **miesf.com.au/pds**។ ការដាក់កំណត់លើការធានារ៉ាប់រងផ្សេងៗមានពន្យល់នៅទំព័រ 3 និង4 នៃកូនសៀវភៅការធានារ៉ាប់រង។

យើងរីករាយនឹងជម្រាបជូនថាការដកប្រាក់ចំនួន $5.60 ក្នុងមួយសប្តាហ៍ ហើយនិងការការពារធានារ៉ាប់រង នឹងនៅបន្តរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2018 ក្នុងពេលដែលមូលនិធិសោធននិវត្តន៍ភាគច្រើនបានបង្កើនតម្លៃធានារ៉ាប់រងរបស់ពួកគេ ឬបង្កើតការការពារធានារ៉ាប់រងកាន់តែមិនល្អ សម្រាប់សមាជិក។

## របៀបទាក់ទងមកយើងខ្ញុំ


Administration Officer
Meat Industry Employees' Superannuation Fund
2nd floor, 62 Lygon Street
CARLTON SOUTH VIC 3053

ទូរស័ព្ទ: 1800 252 099 ឬ
(03) 9662 3861 (សម្រាប់អ្នកហៅទូរស័ព្ទចេញពីទូរស័ព្ទចល័ត)

ទូរសារ: (03) 9662 2430

អ៊ីម៉ែល: fundadmin@miesf.com.au

វិបសាយ: **www.miesf.com.au**